ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ


រដ្ឋបាលជលផល
ក្រុមការងារច្បាប់នៃរដ្ឋបាលជលផល


ឯកសារបណ្តុះបណ្តាល

# ច្បាប់ ស្តីពី ជលផល


រៀបរៀងដោយៈ

ឯកឧត្តម ណៅ ធួក "ប្រធានរដ្ឋបាលជលផល"
លោក លី វុទ្ធី "ប្រធានការិយាល័យអភិវឌ្ឍន៍សហគមន៍"
លោក សំ សត្យា "មន្ត្រីការិយាល័យវិវាទ"



ខែ តុលា ឆ្នាំ ២០០៦



រក្សាសិទ្ធិគ្រប់យ៉ាង

# មាតិកា

ឈ្មោះ ទំព័រ


សេចក្តីផ្តើម: ........................................ ១

ជំពូក ១: អំពីរដ្ឋបាលជលផល និងការគ្រប់គ្រងជលផល ........................................ ២

១. រចនាសម្ព័ន្ធរដ្ឋបាលជលផល ........................................ ២

២. ការគ្រប់គ្រងដោយគោលនយោបាយវិស័យជលផលជាតិ ........................................ ២

៣.តំបន់គ្រប់គ្រងជលផល ........................................ ៣

៤. អំពីដែននេសាទ និងការគ្រប់គ្រងដែននេសាទ ........................................ ៣

៤.១ និយមន័យដែលនេសាទ ........................................ ៣

ក. ដែននេសាទទឹកសាប ........................................ ៤

ខ. ដែននេសាទសមុទ្រ ........................................ ៤

៤.២. ការគ្រប់គ្រងអាជីវកម្ម ........................................ ៥

ក. ឧបករណ៍នេសាទ ........................................ ៥

ខ. ការធ្វើអាជីវកម្មនេសាទ ........................................ ៥

៤.៣. ការគ្រប់គ្រងនាទីព្រៃលិចទឹក និងព្រៃកោងកាង ........................................ ៧

ជំពូក ២: សហគមន៍នេសាទ ........................................ ៨

១. និយមន័យ: ........................................ ៨

២. វិធាននៃការបង្កើត និងការគ្រប់គ្រងសហគមន៍នេសាទ ........................................ ៨

២.១ លក្ខខណ្ឌនៃការបង្កើតសហគមន៍នេសាទ ........................................ ៨

ក. អំពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ........................................ ៨

ខ. កិច្ចព្រមព្រៀង និងផែនទីសហគមន៍នេសាទ ........................................ ៩

គ. អំពីផែនការគ្រប់គ្រងសហគមន៍នេសាទ ........................................ ១០

២.២. លក្ខខណ្ឌសុំចូលជាសមាជិក សិទ្ធិ និងតួនាទីភារកិច្ចរបស់សមាជិកសហគមន៍នេសាទ ........................................ ១១

ក.លក្ខខណ្ឌសុំចូលជាសមាជិកសហគមន៍នេសាទ ........................................ ១១

ខ. សិទ្ធិ និងតួនាទីភារកិច្ចរបស់សមាជិកសហគមន៍នេសាទ ........................................ ១១

គ. សិទ្ធ និងតួនាទីភារកិច្ចរបស់សហគមន៍នេសាទ ........................................ ១២

គ.១. សិទ្ធិសហគមន៍នេសាទ ........................................ ១២

គ.២. តួនាទី ភារកិច្ចរបស់សហគមន៍នេសាទ........................................................ ១៣

ឃ.ការជ្រើសរើសប្រធាន និងគណៈកម្មការសហគមន៍នេសាទ........................................ ១៣

ឃ.១. ការជ្រើសរើសគណៈកម្មការសហគមន៍នេសាទ.................................................. ១៤

ឃ.២. ការជ្រើសរើសប្រធានគណៈកម្មការសហគមន៍នេសាទ........................................... ១៤

៣. ស្ថាប័នគ្រប់គ្រង និងប្រភពថវិការបស់សហគមន៍នេសាទ............................................ ១៤

៣.១. ស្ថាប័នគ្រប់គ្រង ........................................................................... ១៤

ក. តួនាទី និងភារកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ................................ ១៤

ខ. តួនាទី និងភារកិច្ចរបស់រដ្ឋបាលជលផល............................................................ ១៥

៣.២. ប្រភពថវិការបស់សហគមន៍នេសាទ............................................................ ១៥

ជំពូក ៣: ការគ្រប់គ្រងវារីវប្បកម្ម ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មលើផលិតផលជលផល.............. ១៧

១. ការគ្រប់គ្រងវារីវប្បកម្ម............................................................................... ១៧

ក. ការគ្រប់គ្រងវារីវប្បកម្មទឹកសាប.................................................................... ១៧

ខ. ការគ្រប់គ្រងវារីវប្បកម្មសមុទ្រ...................................................................... ១៧

២. ការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្មលើផលិតផលជលផល........................................ ១៨

៣. អំពីបរិស្ថាន ការនាំចូលវារីរុក្ខជាតិ វារីសត្វពីបរទេស និងការចេញលិខិតអនុញ្ញាត..................... ១៨

ជំពូក ៤: នីតិវិធីដោះស្រាយបទល្មើសជលផល.......................................................... ២០

១. ដំណោះស្រាយបទល្មើសជលផលដោយរដ្ឋបាលជលផល............................................... ២០

១.១. អំពីមន្ត្រីនគរបាលយុត្តិធម៌ជលផល............................................................ ២១

១.២. ការចងក្រងសំណុំរឿងសម្រាប់ពិន័យអន្តរការណ៍................................................ ២២

២. ដំណោះស្រាយបទល្មើសជលផលដោយតុលាការ....................................................... ២៣

ក. អំពីអយ្យការអមតុលាការ ខេត្ត/ក្រុង............................................................... ២៤

ខ. អំពីចៅក្រមស៊ើបអង្កេត ឬ សុភាចារបុរស .......................................................... ២៥

គ. អំពីចៅក្រមជំនុំជម្រះ.................................................................................. ២៦

៣.សមត្ថកិច្ចពាក់ព័ន្ធ និងការអនុវត្តសាលក្រម ឬ សាលដីកា.............................................. ២៦

៣.១. សមត្ថកិច្ចពាក់ព័ន្ធ.................................................................................. ២៦

៣.២. ការអនុវត្តសាលក្រម ឬ សាលដីកា.................................................................. ២៧

# សេចក្តីផ្តើម

ច្បាប់ស្តីពីជលផល គឺជាវិធានគតិយុត្តិមួយសម្រាប់គ្រប់គ្រង និងការពារនូវធនធានជលផលធម្មជាតិ ក៏ដូចធនធានកែច្នៃ ការដឹកជញ្ជូនជលផល ការទិញ-លក់ ការអភិរក្ស ការការពារ ការថែរក្សាព្រៃលិចទឹក...ព្រមទាំងអាជ្ញាធរ**រដ្ឋបាលជលផល** ដែលស្ថិតក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមត្ថកិច្ច*ទទួលបន្ទុក* ។

ច្បាប់ស្តីពីជលផលត្រូវបានព្រាង និងរៀបចំឡើងដំបូងដោយបណ្ឌិតច្បាប់នៃធនាគារពិភពលោក រួមជាមួយគណៈកម្មាការបច្ចេកទេសជលផលនៅ ឆ្នាំ១៩៩៩ ។ សេចក្តីព្រាងច្បាប់នេះ ត្រូវបានធ្វើការពិគ្រោះយោបល់ជាបន្តបន្ទាប់ និងច្រើនដង ដើម្បីធ្វើការកែលំអឱ្យបានសមស្របតាមការវិវឌ្ឍន៍របស់សង្គមកម្ពុជា ក៏ដូចជាឱ្យស្របតាមគោលការណ៍ច្បាប់ ប្រពៃណីទំនៀមទំលាប់ ជាពិសេសចំពោះអ្នកនេសាទ អ្នកចិញ្ចឹមត្រី ឬពាណិជ្ជករត្រី ។ល។ ជាមួយគ្នានេះដែរ សេចក្តីព្រាងច្បាប់ស្តីពីជលផលក៏ត្រូវបានការផ្តល់នូវអនុសាសន៍ល្អៗមួយចំនួនអំពីអាជ្ញាធរដែនដី ក្រសួងពាក់ព័ន្ធ សង្គមស៊ីវិល ក្រសួងយុត្តិធម៌ ក្រុមប្រឹក្សាអ្នកច្បាប់នៃគណៈរដ្ឋមន្ត្រី កិច្ចប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី ហើយនៅថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០៦ ត្រូវបានសភាពេញអង្គអនុម័ត។ បន្ទាប់មកទៀត នៅថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៦ ត្រូវបានព្រះមហាក្សត្រទ្រង់ឡាយព្រហស្តលេខាលើព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ប្រកាសឱ្យប្រើប្រាស់ជាផ្លូវការ ។

ជំពូក ១

# ទំពីរដ្ឋបាលជលផល និងការគ្រប់គ្រងជលផល

មុននឹងសិក្សាច្បាប់ស្តីពីជលផល យើងគប្បីស្វែងយល់ពាក្យ **រដ្ឋបាលជលផល** ជាមុនសិន។ រដ្ឋបាលជលផលផ្សំឡើងពីពាក្យ "*រដ្ឋបាល* និង *ជលផល*" ។

**រដ្ឋបាល** = ការថែរក្សារដ្ឋ នគរ ឬ ប្រទេស

**ជលផល** = សំដៅប្រព័ន្ធអេកូឡូស៊ីធម្មជាតិ ឬ សិប្បនិម្មិត ក្រោមទម្រង់ជាដីលិចទឹកដែលគ្របដណ្តប់ទៅដោយទឹកអចិន្ត្រៃយ៍ ឬ ជំនោរ ឬ ទឹកជោរ នាច និងរុក្ខជាតិចម្រុះលិចទឹក ព្រមទាំងធនធានជីវសាស្ត្រដូចជា វារីសត្វ វារីរុក្ខជាតិដែលបង្កកំណើតនៅក្នុងទឹក ។ ចំពោះពាក្យរដ្ឋបាលខាងលើ ហាក់សំដៅតែទៅលើ រដ្ឋបាលសាធារណៈមួយប៉ុណ្ណោះ ( កិច្ចការរដ្ឋ ) ។ ប៉ុន្តែការអនុវត្តជាក់ស្តែង ក្នុងវិស័យឯកជនដូចជា: ក្រុមហ៊ុនសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាលក៏មានរដ្ឋបាលរបស់គេដែរ ។

ដើម្បីឱ្យពាក្យរដ្ឋបាលមានន័យរួម និងជាពិសេសបានត្រឹមត្រូវតាមន័យនីតិរដ្ឋបាលនោះ ពាក្យរដ្ឋបាលមានន័យថា : "*សកម្មភាពគ្រប់គ្រង*" ។

ដូច្នេះ "*រដ្ឋបាលជលផលមានន័យថា ជាសកម្មភាពគ្រប់គ្រងធនធានជលផល ក្នុងនោះ រួមមានធនធានជលផលធម្មជាតិ ធនធានជលផលសិប្បនិម្មិតទាំងទឹកសាប ទាំងសមុទ្រ រួមទាំងការដឹកជញ្ជូនជលផល និងការគ្រប់គ្រងដែននេសាទផងដែរ*" ។

## ១. រចនាសម្ព័ន្ធរដ្ឋបាលជលផល

រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រងចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល ( មាត្រា ៦ ច្បាប់ស្តីពីជលផល ២០០៦ ) ។

រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

## ២. ការគ្រប់គ្រងដោយគោលនយោបាយវិស័យជលផលជាតិ

ដើម្បីគ្រប់គ្រងវិស័យជលផលប្រកបដោយនិរន្តរភាព ច្បាប់ស្តីពីជលផលតម្រូវឱ្យមានគោលនយោបាយវិស័យជលផលជាតិ មានគណៈកម្មាធិការគ្រប់គ្រងដែលដឹកនាំដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ព្រមទាំងមានសមាជិកមួយចំនួនមកពីក្រសួងពាក់ព័ន្ធ ( មាត្រា ១៤ ច្បាប់ស្តីពីជលផល ២០០៦ ) ។

លើសពីនេះទៅទៀត រដ្ឋបាលជលផលត្រូវរៀបចំផែនការគ្រប់គ្រងវិស័យជលផលជាតិ ស្របតាមគោលនយោបាយវិស័យជលផលជាតិ ហើយផែនការនេះតម្រូវឱ្យមានការចូលរួមទូលំទូលាយពីគ្រប់អាជ្ញាធរពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន។ ផែនការ តម្រូវឱ្យធ្វើការពិនិត្យ និងសើរើរៀងរាល់ប្រាំឆ្នាំ (៥) ម្តងដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌ និងកាលៈទេសៈផ្លាស់ប្តូរ។ គណៈកម្មាធិការជាតិរៀបចំគោលនយោបាយវិស័យជលផលជាតិ ត្រូវផ្តល់អនុសាសន៍ជូនរាជរដ្ឋាភិបាលលើផែនការគ្រប់គ្រងវិស័យជលផលជាតិដែលបានសើរើ ( មាត្រា ១៥ ច្បាប់ស្តីពីជលផល ២០០៦ )។

រដ្ឋបាលជលផល ត្រូវទទួលបាននូវថវិកាអំពីចំណូលលើវិស័យជលផល ជាអទិភាពតាមនីតិវិធីហិរញ្ញវត្ថុ សម្រាប់បំរើឱ្យការងារកែទម្រង់វិស័យជលផលដូចជា ការស្រាវជ្រាវ ការអភិរក្ស និងការថែរក្សាធនធានជលផលប្រកបដោយនិរន្តរភាព។

ច្បាប់ស្តីពីជលផល បានបង្កើតឡើងនូវ*ទិវាមច្ឆជាតិ* ដោយតម្រូវឱ្យប្រារព្ធធ្វើនៅថ្ងៃទី ០១ ខែ កក្កដា ជារៀងរាល់ឆ្នាំក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ឬ ព្រះរាជតំណាង (មាត្រា ១៧ ច្បាប់ស្តីពី ជលផល ២០០៦)។

## ៣. តំបន់គ្រប់គ្រងជលផល

តំបន់គ្រប់គ្រងជលផល គឺជាកន្លែងនេសាទគ្រប់ប្រភេទ កន្លែងអភិរក្សជលផល តំបន់ឆ្នេរសមុទ្រ តំបន់ផ្កាថ្ម ទំនាបលិចទឹកក្នុងរដូវទឹកដំឡើង នាទីព្រៃលិចទឹក ព្រៃកោងកាង ដូចមានចែងក្នុងមាត្រា ១០ និងមាត្រា ១១ នៃច្បាប់ស្តីពីជលផលឆ្នាំ ២០០៦។

ការបង្កើត ការរំសាយ តំបន់គ្រប់គ្រងជលផល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ ការផ្តល់កម្មសិទ្ធិក្នុងតំបន់គ្រប់គ្រងជលផលអាចប្រព្រឹត្តទៅបាន លុះត្រាមានការសិក្សាវាយតម្លៃពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទជាមុន ។ ចំណែកនីតិវិធីនៃការបង្កើត រំសាយតំបន់គ្រប់គ្រងជលផលត្រូវកំណត់ដោយអនុក្រឹត្យ ។

## ៤ .អំពីដែននេសាទ និងការគ្រប់គ្រងអាជីវកម្មនេសាទ

### ៤.១. និយមន័យដែននេសាទ:

ដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋ ។ ការប្រើប្រាស់ដែននេសាទក្រៅពីគោលបំណងវិស័យជលផល ត្រូវសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( មាត្រា ៩ ច្បាប់ស្តីពីជលផល ឆ្នាំ ២០០៦)។ ដែននេសាទរួមមាន: ដែនដីលិចទឹកជាអចិន្ត្រៃយ៍ជាអាទ៍: សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ ឬដែនដីដែលទទួលរបបទឹកទន្លេមេគង្គជាអាទ៍: ត្រពាំង រណ្តៅ វាលភក់ ល្បាប់ វាលទំនាបលិចទឹកក្នុងរដូវទឹកដំឡើង និងនាទីព្រៃលិចទឹក ព្រមទាំងដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រជាអាទិ៍: នាទីព្រៃកោងកាង ដែលមានតួនាទីសំខាន់